# ព្រះរាជក្រម

នស/រកម/០៦១៨/ ០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល
លេខ
ថ្ងៃទី ឆ្នាំ ម៉ោង
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឱ្យប្រើ

## ដោយព្រះរាជក្រមលេខ

## នស/រកម/០៧០១/០៩

## ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០១ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា៣.-ថ្មី**

ធនធានរ៉ែគឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័នដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ត្បូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម គ្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន ។

ប្រតិបត្តិការធនធានរ៉ែគឺជាការធ្វើសកម្មភាព បុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

បុរេសនាគឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាបណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

ការស្វែងរុករកគឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់ សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្ររូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ។

អាជីវកម្មធនធានរ៉ែគឺជាប្រតិបត្តិការជីកយកធនធានរ៉ែ ដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីជម្រករ៉ែ ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម ។ ដោយឡែកការលក់ដូរ ការនាំចេញ ការនាំចូលលោហធាតុមានតម្លៃ ត្បូងថ្មមានតម្លៃដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ។

ផលិតផលរ៉ែសំដៅដល់ផលិតផលរ៉ែដែលបានមកពីការធ្វើប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាបណ្ណធនធានរ៉ែពីក្រសួងទទួលបន្ទុកវិស័យរ៉ែ ។

**មាត្រា២៣.-ថ្មី**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវចាត់តាំងមន្ត្រីអធិការកិច្ចធនធានរ៉ែដើម្បីពិនិត្យការអនុវត្តច្បាប់នេះ ។

មន្ត្រីអធិការកិច្ចធនធានរ៉ែមានសិទ្ធិ ៖

- ធ្វើអធិការកិច្ចក្នុងតំបន់អាជ្ញាបណ្ណដើម្បីកំណត់វាយតម្លៃអំពីស្ថានភាពប្រតិបត្តិការធនធានរ៉ែ និងពិនិត្យអនុលោមភាពតាមច្បាប់ គោលការណ៍បច្ចេកទេស និងបទប្បញ្ញត្តិស្តីពីសុវត្ថិភាព និងការការពារបរិស្ថាននិងសង្គម
- តម្រូវឱ្យផ្អាកជាបណ្តោះអាសន្ន ឬកែប្រែប្រតិបត្តិការធនធានរ៉ែក្នុងករណីដែលប្រតិបត្តិការធនធានរ៉ែនោះអាចបង្កគ្រោះថ្នាក់ ឬហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាពពលកម្ម និង/ឬបរិស្ថាន
- ផ្អាកឬឃាត់ទុកមធ្យោបាយផលិតកម្មដែលធ្វើប្រតិបត្តិការធនធានរ៉ែល្មើសច្បាប់ ឬមធ្យោបាយដឹកជញ្ជូនធនធានរ៉ែដោយខុសច្បាប់ ឬមិនត្រឹមត្រូវតាមគោលការណ៍បច្ចេកទេស

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មន្ត្រីអធិការកិច្ចធនធានរ៉ែទទួលនីតិសម្បទាឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

ឯកសណ្ឋាន និងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៣០._ថ្មី**

ហាមដាច់ខាតការដឹកជញ្ជូនធនធានរ៉ែឬផលិតផលរ៉ែចេញពីការដ្ឋាន ក្នុងករណីដែលធនធានរ៉ែ ឬផលិតផលរ៉ែនោះមិនទាន់បានបង់សួយសារ ឬគ្មានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

ហាមដាច់ខាតការនាំចេញធនធានរ៉ែ ឬផលិតផលរ៉ែទៅក្រៅប្រទេសដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

**មាត្រា៣៣._ថ្មី**

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែដោយគ្មានអាជ្ញាបណ្ណធនធានរ៉ែត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែចំនួនពី ៥០០ ០០០(ប្រាំសែន)រៀល ទៅ ១ ០០០ ០០០(មួយលាន)រៀល ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៣ ០០០ ០០០(បីលាន)រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។

**មាត្រា៣៤._ថ្មី**

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា៧ ឬមាត្រា៨ នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែចំនួនពី ៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១០ ០០០ ០០០ (ដប់លាន)រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន)រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ២(ពីរ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។

**មាត្រា៣៥._ថ្មី**

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយគ្មានអាជ្ញាបណ្ណធនធានរ៉ែ ឬល្មើសនឹងមាត្រា៧ ឬមាត្រា៨ នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែចំនួនស្មើនឹង២(ពីរ)ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែ តាមរយៈពេលដែលផលរ៉ែត្រូវបានជីកយកដោយផ្អែកលើទំហំឧបករណ៍ គ្រឿងចក្រផលិតកម្មប្រើប្រាស់ និងបរិមាណរ៉ែដែលមានក្នុងទីតាំងនោះ ឬត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែ ចំនួន ១ ៥០០ ០០០(មួយលានប្រាំសែន)រៀលក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃដែល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

បុគ្គលនោះប្រព្រឹត្តខុសរហូតដល់ថ្ងៃដែលសកម្មភាពប្រតិបត្តិការជីកយករ៉ែនោះត្រូវបានបញ្ឈប់ ។ ការផាកពិន័យនេះត្រូវធ្វើឡើងដោយជ្រើសរើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដងនៃប្រាក់ដែលត្រូវផាកពិន័យដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត ។ ឧបករណ៍ គ្រឿងចក្រនិងមធ្យោបាយផលិតកម្មផ្សេងទៀតពាក់ព័ន្ធនឹងអំពើល្មើសនេះត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា៣៦._ថ្មី**

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណធនធានរ៉ែអស់សុពលភាព ឬក្រៅដែនអាជ្ញាបណ្ណ ឬមិនបានដាក់ពាក្យស្នើសុំពន្យារបន្តអាជ្ញាបណ្ណធនធានរ៉ែទាន់ពេលវេលា ត្រូវផាកពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៣៥ថ្មី នៃច្បាប់នេះ ។

សម្បទានិកដែលមិនគោរពតាមលក្ខខណ្ឌដូចមានបញ្ញត្តិក្នុងអាជ្ញាបណ្ណធនធានរ៉ែត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែ ចំនួនពី ៥ 000 000(ប្រាំលាន)រៀល ទៅ ៥០ 000 000 (ហាសិបលាន)រៀល ដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត ។

**មាត្រា៣៧._ថ្មី**

បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា៣០ថ្មី នៃច្បាប់នេះត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែ ចំនួនទ្វេដងនៃតម្លៃធនធានរ៉ែ ឬផលិតផលរ៉ែដែលបានដឹកចេញពីការដ្ឋាន ឬត្រូវដកហូតអាជ្ញាបណ្ណធនធានរ៉ែ ឬត្រូវទទួលទោសទាំងពីរ ។

បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា៣០ថ្មី នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនទ្វេដងនៃតម្លៃធនធានរ៉ែ ឬផលិតផលរ៉ែដែលបាននាំចេញទៅក្រៅប្រទេស ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។

**មាត្រា៣៨._ថ្មី**

សម្បទានិកដែលមិនអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចធនធានរ៉ែចុះត្រួតពិនិត្យដូចមានចែងក្នុងមាត្រា២៣ថ្មី នៃច្បាប់នេះត្រូវផាកពិន័យជាប្រាក់ដោយក្រសួងទទួលបន្ទុកវិស័យរ៉ែ ចំនួនពី៥ 000 000(ប្រាំលាន)រៀលទៅ ១០ 000 000(ដប់លាន)រៀល ឬត្រូវព្យួរទុកអាជ្ញាបណ្ណធនធានរ៉ែរយៈពេលមិនលើសពី៦ (ប្រាំមួយ)ខែ ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវដកហូតអាជ្ញាបណ្ណធនធានរ៉ែជាស្ថាពរ ។

**មាត្រា៣៩._ថ្មី**

បុគ្គលណាដែលមិនមែនជាម្ចាស់កម្មសិទ្ធិដីស្របច្បាប់ ហើយធ្វើឱ្យរាំងស្ទះដល់ប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាបណ្ណធនធានរ៉ែត្រឹមត្រូវតាមច្បាប់នោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១ 000 000(មួយលាន)រៀល ទៅ ៤ 000 000(បួនលាន)រៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ២(ពីរ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៤០._ថ្មី**

នីតិវិធីនៃការផាកពិន័យលើអំពើល្មើសដូចមានចែងក្នុងច្បាប់នេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្ដីសម្រេចអំពីទណ្ឌកម្មរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ដូចមានចែងនៅក្នុងច្បាប់នេះមានសិទ្ធិធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេច ។

ប្រាក់ផាកពិន័យ ប្រាក់ពិន័យតាមសាលក្រម ឬសាលដីការបស់តុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាង ដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋត្រូវបង់ចូលថវិកាជាតិ ។

រាជរដ្ឋាភិបាលអាចសម្រេចផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើសក្នុងវិស័យរ៉ែ ។

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ)នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្ដីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ ។

**មាត្រាពីរ._**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨

នស/រកម.១៨០៦.៦៥០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
**ហត្ថលេខា**
**ស៊ុយ សែម**

លេខៈ៦៦២ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**